# សារបានព្រះវិហារវត្តពោធិ៍ជំរី

វត្តពោធិ៍ជំរី ស្ថិតនៅក្នុងសង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង។ ព្រះវិហារវត្តនេះជាព្រះវិហារជហ្វាបួនដ៏ធំទូលាយ ហើយបើផ្អែកតាមសាវតារវត្តឱ្យដឹងថាព្រះវិហារកសាងឡើងតាំងពីរវាងពាក់កណ្ដាលទសវត្សរ៍ទី៤០ ដែលបានឆ្លងកាត់សង្គ្រាមជាច្រើនជំនាន់មកហើយ (រូបលេខ១)។ អ្នកស្រុកនិទានថា ដើមឡើយនៅក្នុងព្រះវិហារវត្តធ្លាប់តម្កល់ព្រះពុទ្ធបដិមាសំរិទ្ធមួយព្រះអង្គដ៏មានបារមីខ្លាំងពូកែ។ ប៉ុន្តែជាអកុសលនៅសម័យកម្ពុជាប្រជាធិបតេយ្យ គេបានយកព្រះវិហារធ្វើជាកន្លែងចិញ្ចឹមសត្វ ហើយក្នុងរវាងទសវត្សរ៍ទី៩០ ព្រះបដិមាសំរិទ្ធត្រូវជនទុច្ចរិតចូលលួចយកទៅបាត់ទាំងយប់។



រូបលេខ១ ព្រះវិហារវត្តពោធិ៍ជំរីមើលពីជ្រុងនារតី

ជាការពិត បើផ្អែកតាមផ្ទាំងចារឹកចារជាប់ជញ្ជាំងខាងលិចនៃព្រះវិហារវត្តពោធិ៍ជំរី (រូបលេខ២) ឱ្យដឹងថាចាប់តាំងពីកកើតវត្តមក វត្តនេះបានការផ្តួចផ្តើមជ្រោមជ្រែងខ្លាំងពីសំណាក់ព្រះសង្ឃមួយអង្គព្រះនាម យក់ យិម ដែលមាននាទីជាព្រះចៅអធិការវត្ត និងជាអតីតអនុគណគណៈមហានិយាយ ដឹកនាំរៀបចំបរិវេណវត្ត ចាក់ដីបំពេញថ្លុកត្រពាំងឱ្យ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

រៀបស្មើ ដីកស្រះ១ និងសាងកុដិក្បឿងចំនួន៨ នៅក្នុងឆ្នាំ១៩២៥។ លុះដល់ឆ្នាំ១៩៣៦ ព្រះអង្គបានដឹកនាំកសាងសាលាបាលី សាលាសម្មាធិ ដាវគម្ពីរព្រះត្រៃបិដកតម្កល់ទុកក្នុងសាលា ហើយនិមន្តអាចារ្យមកបង្រៀនផង។ ចូលដល់ឆ្នាំ១៩៤៦ ព្រះអង្គបានដឹកនាំពុទ្ធបរិស័ទកសាងព្រះវិហារជាថ្មី។ ដូច្នេះតាមរយៈសេចក្តីចុងក្រោយនេះ បានន័យថាព្រះវិហារវត្តពោងដំរីកកើតឡើងយូរយារណាស់មកហើយ។



រូបលេខ២ ផ្ទាំងចារឹកអំពីសវតារវត្តពោងដំរី

ដូចបានបញ្ជាក់មកខាងលើ ព្រះវិហារវត្តពោងដំរីជាទម្រង់ព្រះវិហារជហ្វាបួនមួយបែបដែលសាងសង់ឱ្យមានលក្ខណៈធំទូលាយជាងព្រះវិហារជហ្វាបួនផ្សេងៗ។[១] ដំបូលព្រះវិហារ គេសង់ឡើងឱ្យមានពងជ្រាលចុះសងខាងបីថ្នាក់ ហើយប្រក់ប្រគេទក្បឿងលោង (គេពុំចាំថាជួសជុលឆ្នាំណាឡើយ) (រូបលេខ៣-២)។ ព្រះវិហារនេះសង់នៅលើខឿនថ្មខ្ពស់បីថ្នាក់ មានជណ្តើរឡើងតែផ្នែកខាងមុខ និងខាងក្រោយ ព្រមទាំងមានទ្វារ

[១] សូមអានបន្ថែម "សំណង់នៅតាមវត្ត" ដោយ ព្រាប ចាន់ម៉ារ៉ា

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ចូលខាងក្រោយពីរ ខាងមុខបី និងចំហៀងសងខាងម្ខាងពីរ (រូបលេខ២៥)។ ជុំវិញព្រះវិហារមានសសរបេតុងមូលធំៗ និងជញ្ជាំងរៀបឥដ្ឋបូកកំបោរបាយអរ ទ្រដំបូលនិងគ្រឿងបង្គុំឈើផ្នែកខាងលើ។ មិនតែប៉ុណ្ណោះ នៅជុំវិញខឿនព្រះវិហារ គេសង្កេតឃើញមានចេតិយបុរាណៗដែលមានសភាពបាក់បែកមួយចំនួនគួរឱ្យកត់សម្គាល់ (រូបលេខ២៦-៧)។



រូបលេខ២៣ ព្រះវិហារមើលពីក្រោយ



រូបលេខ២៤ ដំបូលព្រះវិហារប្រក់ក្បឿងរលោង



រូបលេខ២៥-៧ ខឿនព្រះវិហារ និងចេតិយបុរាណជុំវិញ

ដោយឡែក ប្រសិនបើមើលលម្អិតលើការតុបតែងនៅតាមចុងដំបូល គេឃើញមានលម្អដោយនាគបែង ហើយតាមក្បាលសសរជុំវិញ លម្អដោយគ្រុឌនិងអែប៉ា ព្រមទាំងមានក្បាច់រងស្បូវចាក់ពុម្ពស៊ីម៉ងត៍យ៉ាងល្អវិចិត្រផង (រូបលេខ២៨)។ រីឯក្បាច់លម្អតាមសសរជាប់ជញ្ជាំង និងក្បាច់លម្អស៊ុមទ្វារ-បង្អួចទាំងអស់ជុំវិញព្រះវិហារ ក៏ប្រើជាប្រភេទជាក្បាច់ពុម្ពស៊ីម៉ងត៍ដែរ។ ប៉ុន្តែយ៉ាងណាក្តី គេសម្គាល់ឃើញសន្ទឹកទ្វារ-បង្អួចនៃព្រះវិហារ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

នេះ ជាប្រភេទសន្ទឹកទ្វារ-បង្អួចធ្វើអំពីឈើលាតយ៉ាងសាមញ្ញ ពុំមានរចនាក្បាច់លម្អអ្វីច្រើនឡើយ ពោលគឺមានតែក្បាច់លើបន្ទះឈើត្រង់ចុងក្ដារសន្ទឹកទ្វារ-បង្អួចទល់មុខគ្នាតែប៉ុណ្ណោះ (រូបលេខ៩)។



រូបលេខ៨ ការលម្អរង្សួរនិងក្បាលសសរជុំវិញ



រូបលេខ៩ ការលម្អស៊ុមទ្វារនិងសសរជាប់ជញ្ជាំង

ចំណែកឯការលម្អលើហោជាង៍នៃព្រះវិហារវត្តពោធិ៍ដំរីនេះ គេសង្កេតឃើញមានលក្ខណៈដូចគ្នាទាំងសងខាង ពោលគឺសន្ទឹកក្បាច់ដូចគ្នាទាំងហោជាង៍មុខ និងហោជាង៍ក្រោយ។ នៅត្រង់កណ្ដាលផ្ទៃហោជាង៍ទាំងពីរ គឺគេរចនាឱ្យមានជារូបដើមពានទ្រគម្ពីរ និងផ្ចិតចាមរ ហើយនៅចុងកំពូលមានពន្លឺរង្សី។ ស្ថិតនៅសងខាងរូបនេះ គឺមានឆ័ត្ររួតមួយគូ ព្រមទាំងមានផ្ទាក់ក្បាច់ភ្ញីទេសលាយព័ទ្ធជុំវិញពេញផ្ទៃហោជាង៍។ តាមរយៈលក្ខណៈក្បាច់លម្អលើហោជាង៍នេះ គេមើលឃើញដូចគ្នាទាំងស្រុងនឹងក្បាច់ហោជាង៍វត្តសំសមី (កសាងឆ្នាំ១៩៣១ បញ្ចុះសីមាឆ្នាំ១៩៤៤) ដែលស្ថិតក្នុងក្រុងព្រៃវែង។[២] សូមរម្លឹកថាបើផ្អែកតាមចារឹកមួយផ្ទាំងខាងលើ គេដឹងថាព្រះតេជគុណ យក់ យិម គឺជាព្រះចៅអធិការវត្តពោធិ៍ដំរី ដែលព្រះអង្គធ្លាប់គង់នៅរៀនសូត្រក្នុងវត្តសំសមី មុននឹងនិមន្តមកធ្វើជាព្រះចៅអធិការវត្តពោធិ៍ដំរី។

---

[២]សូមអាន "ព្រះវិហារវត្តសំសមី" ដោយ ហឿន សុវណ្ណមរកត ផ្សាយលើគេហទំព័រ https://ams.com.kh/khmercivilization/detail/23503 ថ្ងៃទី២ ខែសីហា ឆ្នាំ២០២២

អត្ថបទដោយ៖ ហឿន សុវណ្ណមរកត





រូបលេខ១០-១១ ក្បាច់លម្អលើហោជាងមុខ-ក្រោយលើព្រះវិហារវត្តពោងដំរី

ចំពោះផ្នែកខាងក្នុងព្រះវិហារ គេសង់ឡើងឱ្យមានបីល្វែងយ៉ាងធំទូលាយ ពោលគឺល្វែងគ្រឹះនៅកណ្ដាល និងអមដោយរបៀងសងខាងដូចព្រះវិហារជហ្វាបួនទូទៅដែរ (រូបលេខ១២)។ ចំណែកឯនៅផ្នែកចុងខាងលិចនៃល្វែងគ្រឹះ គឺជាបល្ល័ង្កតម្កល់ព្រះដីវ៍ធំមួយ។ សូមរម្លឹកថា ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ គេបានយកព្រះវិហារវត្តនេះធ្វើជាកន្លែងចិញ្ចឹមជ្រូក។ ក្រោយសង្គ្រាមបញ្ចប់ទៅ ព្រះសង្ឃ និងពុទ្ធបរិស័ទបានរៀបចំជួសជុលព្រះវិហារវត្តនេះឡើងវិញជាច្រើនលើកច្រើនសារ។ ក្នុងឆ្នាំ១៩៨១ បានកសាងបល័ង្ក និងព្រះដីវ៍ថ្មី (រូបលេខ១៣) ហើយរហូតមកដល់ក្នុងឆ្នាំ២០០៨ ទើបគេបានលុបគំនូរចាស់លើជញ្ជាំងជុំវិញព្រះវិហារចោល ហើយសាងគំនូរជាថ្មីម្ដងទៀត។ ទន្ទឹមនឹងនេះ ផ្អែកលើសំណេរកត់ត្រាក្នុងព្រះវិហារឱ្យដឹងថា ទាំងបល្ល័ង្ក ព្រះដីវ៍ និងគំនូរថ្មីក្នុងព្រះវិហារ គឺជាស្នាដៃជាងឈ្មោះ គៀក ទ្រី។ គំនូរទាំងនោះសោត គឺជាគំនូររបៀបថ្មីនិយាយពីរឿងពុទ្ធប្រវត្តិ និងរឿងជាតកដូចបណ្ដាព្រះវិហារសង់ថ្មីៗដែរ (រូបលេខ១៤-១៦)។





រូបលេខ១២-១៣ ផ្នែកខាងក្នុង និងព្រះដីវ៍ថ្មីព្រះវិហារវត្តពោងដំរី

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត









រូបលេខ១៤-១៧ គំនូរថ្មីក្នុងព្រះវិហារវត្តពោងដំរី គូរឆ្នាំ២០០៨

សរុបសេចក្តីមក ព្រះវិហារវត្តពោងដំរី គឺជាស្ថាបត្យកម្មព្រះពុទ្ធសាសនាចុងសម័យបាពាំង ដែលធ្លាប់បានឆ្លងកាត់ការបំផ្លិចផ្លាញក្នុងសម័យសង្គ្រាម និងបានជួសជុលថែទាំគោរពបូជារាប់ជំនាន់មកហើយ។ ទម្រង់ស្ថាបត្យកម្ម ការលម្អស្ថាបត្យកម្ម និងទឹកដៃសិល្បៈគំនូរ ក៏បង្ហាញឱ្យឃើញពីការវិវឌ្ឍ និងការនិយមចូលចិត្តរបស់អ្នកស្រុកក្នុងផ្នែកសិល្បៈព្រះពុទ្ធសាសនាដែរ។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង

ព្រាប ចាន់ម៉ារ៉ា

២០១៧, *សំណង់នៅតាមវត្ត*, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ

ហឿន សុវណ្ណមរកត

២០២២, "ព្រះវិហារវត្តសំសមី", ផ្សាយលើគេហទំព័រ

*ttps://ams.com.kh/khmercivilization/detail/23503*

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION